**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច**
*ដេប៉ាតឺម៉ង់គណនេយ្យនិងគ្រប់គ្រង*

# កិច្ចដំណើរការគម្រោងរបស់ ប្រធានបទស្រាវជ្រាវ

**បណ្ឌិត ង៉ាន់ ស៊ុនដេត**
*សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ*
*និងវិទ្យាសាស្ត្រសេដ្ឋកិច្ច*

*២២ ខែធ្នូ ឆ្នាំ ២០២០*

# *អារម្ភកថា*

*ការសិក្សានៅសាកលវិទ្យាល័យ កិច្ចការស្រាវជ្រាវដើរតួនាទីសំខាន់ក្នុងការរុករករបកគំហើញថ្មីៗជាបន្តបន្ទាប់ ។ ផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យដាក់គោលដៅលើកទឹកចិត្តដល់អ្នកសិក្សាស្រាវជ្រាវឲ្យខិតខំរិះរកគំនិតច្នៃប្រឌិតយ៉ាងណាដើម្បីរកឲ្យបាននូវសមិទ្ធផលថ្មីសម្រាប់បម្រើផលប្រយោជន៍ដល់មហាជនទាំងខាងផ្នែកសេដ្ឋកិច្ចនិងសង្គម។*

*និស្សិតសាកលវិទ្យាល័យគឺជាអ្នកស្រាវជ្រាវ ។ ការស្រាវជ្រាវចាំបាច់ត្រូវមានគោលការណ៍យន្តការ និងការគាំទ្រផ្សេងៗមានដូចជាបច្ចេកទេស ការណែនាំ ហិរញ្ញវត្ថុ ការគាំទ្រនិងបង្កើតភាពងាយស្រួល។ល។ ដើម្បីឲ្យពួកគាត់អាចដំណើរការរៀបចំគម្រោងស្រាវជ្រាវទទួលបានជោគជ័យនិងមានលទ្ធផលល្អក្នុងការសិក្សារបស់ពួកគាត់។*

*សាកលវិទ្យាល័យមានភាពល្បីល្បាញដោយសារ មានការរីកចម្រើនខាងផ្នែកស្រាវជ្រាវនិងអភិវឌ្ឍន៍។ ឯកសារស្រាវជ្រាវជាអត្ថបទវិទ្យាសាស្ត្រពិពណ៌នាអំពីហេតុការណ៍ដែលបានកើតហើយនិងកំពុងបន្តនិរន្តរភាពនៅក្នុងពេលបច្ចុប្បន្ន ទុកជាមធ្យោបាយសម្រាប់ការស្រាវជ្រាវ ដល់អ្នកសិក្សាស្រាវជ្រាវផ្សេងទៀតបានដឹង។ ដូច្នេះ ឯកសារណែនាំស្តីពី «កិច្ចដំណើរការគម្រោងរបស់ប្រធានបទស្រាវជ្រាវ» ដែលកំពុងស្ថិតក្នុងដៃរបស់លោក អ្នកនាងកញ្ញានេះគឺជាអត្ថបទខ្លីមួយដែលមានការពន្យល់គន្លឹះមួយចំនួន ទុកដូចជាការបង្ហាញផ្លូវមួយដល់អ្នកសិក្សាស្រាវជ្រាវវ័យក្មេងដែលនៅមានបទពិសោធន៍តិចតួចនៅឡើយ ដើម្បីបង្កើនសមត្ថភាពបន្ថែមឆ្ពោះទៅកាន់គោលដៅនៃភាពជោគជ័យបានទាន់ពេលវេលា។*

*ស្នាដៃនេះឧទ្ទិសដល់អ្នកម្តាយដែលបានខិតខំចិញ្ចឹមថែរក្សាកូនទុកជាសេចក្តីកត្តញ្ញូ។*

*ង៉ាន់ ស៊ុនដេត*

# មាតិកា

0. គំនូសចង្អុលបង្ហាញកិច្ចដំណើរការគម្រោងប្រធានបទស្រាវជ្រាវ................................ ៤
1. សេចក្ដីផ្ដើម................................................................................................ ៥
I. ការជ្រើសរើសប្រធានបទ ................................................................................ ៦
II. ការកំណត់ប្រធានបទស្រាវជ្រាវ ...................................................................... ៦
III. ការស្នើសុំចុះឈ្មោះប្រធានបទស្រាវជ្រាវ ............................................................. ៦
IV. ដំណើរការសរសេរអត្ថបទស្រាវជ្រាវ.................................................................... ៦
V. ការធ្វើបទបង្ហាញសាកល្បង ............................................................................. ៧
VI. ការបោះពុម្ពអត្ថបទស្រាវជ្រាវ........................................................................... ៧
VII. ការស្នើសុំការពារបញ្ចប់កិច្ចការស្រាវជ្រាវ.............................................................. ៩
VIII. ការធ្វើបទបង្ហាញ និងការពារអត្ថបទស្រាវជ្រាវ ....................................................... ៩
IX. លទ្ធផលស្រាវជ្រាវ........................................................................................ ៩
សេចក្ដីសន្និដ្ឋាន................................................................................................ ១០

## គំនូសចង្អុលបង្ហាញដំណើរការគម្រោងស្រាវជ្រាវប្រធានបទ




**កំណត់សម្គាល់៖** អ្នកស្រាវជ្រាវគឺជានិស្សិតឬបេក្ខជនស្នើសុំសរសេរអត្ថបទស្រាវជ្រាវបញ្ចប់ការសិក្សានៅថ្នាក់បរិញ្ញាបត្រឬថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

# សេចក្តីផ្តើម

ការស្រាវជ្រាវជាលទ្ធផលយ៉ាងសំខាន់មួយនៃការសិក្សានៅថ្នាក់ឧត្តមសិក្សា។ និស្សិតដែលសិក្សានៅឆ្នាំបញ្ចប់ភូមិសិក្សា[1]នីមួយៗ អាស្រ័យទៅតាមជំនាញ៖ មានជំនាញខ្លះតម្រូវឲ្យនិស្សិតថ្នាក់បញ្ចប់ការសិក្សាសរសេរអត្ថបទស្រាវជ្រាវ ឬ របាយការណ៍ស្រាវជ្រាវគ្រប់គ្នា ជំនាញខ្លះទៀតតម្រូវឲ្យនិស្សិតថ្នាក់បញ្ចប់ការសិក្សាធ្វើការជ្រើសរើសការប្រឡងបញ្ចប់ការសិក្សា ឬ ធ្វើការស្រាវជ្រាវសរសេររបាយការណ៍ សារណា ឬ និក្ខេបបទដើម្បីបញ្ចប់ការសិក្សាជំនួសឲ្យការប្រឡងបញ្ចប់ការសិក្សា។

គោលបំណងរបស់អត្ថបទនេះគឺណែនាំនិស្សិត ឬបេក្ខជនដែលត្រូវសរសេរអត្ថបទស្រាវជ្រាវទទួលបានផ្លូវគំនិតថ្មីៗទៅកាន់ការងារស្រាវជ្រាវបានឆាប់រហ័ស និងមានប្រសិទ្ធភាពក្នុងការរៀបចំកិច្ចការស្រាវជ្រាវបានទាន់ពេលវេលា។

អត្ថប្រយោជន៍នៃការស្រាវជ្រាវ អ្នកសរសេរអត្ថបទស្រាវជ្រាវមានឱកាសបង្ហាញសមត្ថភាពទៅកាន់ទីផ្សារពលកម្មទទួលបានចំណេះដឹងថ្មីដែលទាក់ទងនឹងជំនាញដែលបានសិក្សា ព័ត៌មានទីផ្សារ និងផ្សេងៗច្រើនទៀត ជាពិសេសនិស្សិតទទួលបានបទពិសោធន៍ក្នុងការរៀបចំគម្រោងស្រាវជ្រាវអាជីវកម្ម និងសរសេរអត្ថបទរបាយការណ៍បានល្អ។

ខាងក្រោមនេះជាគំនូសសម្រាប់ពន្យល់បង្ហាញអត្ថប្រយោជន៍នៃកិច្ចការស្រាវជ្រាវ៖




Source: ( Sophie Boutillier et al, 2002)

[1] ជាឆ្នាំចុងក្រោយនៃថ្នាក់បរិញ្ញាបត្រ(ឆ្នាំទី៤), ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ រយៈពេលសិក្សាមានចំនួន២ឆ្នាំ(ឆ្នាំទី២ជាឆ្នាំបញ្ចប់)។

នៅក្នុងអត្ថបទខ្លីខាងក្រោមនេះ គឺជាការបង្ហាញនូវគោលការណ៍មួយចំនួនដែលបានអនុវត្តន៍ជាញឹកញាប់នៅក្នុងកិច្ចការស្រាវជ្រាវ តែមិនមែនជាក្បួនទូទៅទេ វាគ្រាន់តែជាសេចក្តីណែនាំខ្លះៗដល់អ្នកស្រាវជ្រាវវ័យក្មេងធ្វើការពិចារណា រកដំណោះស្រាយមុនឈានទៅធ្វើកិច្ចការស្រាវជ្រាវឲ្យបានជោគជ័យ។

## I. *ការជ្រើសរើសប្រធានបទ*

ការជ្រើសរើសប្រធានបទស្រាវជ្រាវមួយត្រូវធ្វើការប្រមូលផ្តុំគំនិត ទស្សនៈឲ្យបានច្រើនតាមរយៈការអាន ការសង្កេត ការស្តាប់ព័ត៌មាន ការពិភាក្សាជាមួយអ្នកមានបទពិសោធន៍និងបូករួមជាមួយបទពិសោធន៍ និងគំនិតផ្ទាល់ខ្លួនផងទើបអាចរកឃើញបញ្ហា ឬកម្មវត្ថុមួយចំនួនមករៀបចំធ្វើជាប្រធានបទសម្រាប់ដាក់ស្នើសុំធ្វើការស្រាវជ្រាវ។ បន្ថែមពីនេះការទទួលបានការគាំទ្រគំនិតពីសាស្ត្រាចារ្យជំនាញកាន់តែប្រសើរ។

## II. *ការកំណត់ប្រធានបទ*

ការកំណត់យកប្រធានបទជាក់លាក់មួយដាក់ស្នើសុំធ្វើការស្រាវជ្រាវ បេក្ខជនត្រូវធ្វើការពិគ្រោះយោបល់ជាមួយសាស្ត្រាចារ្យណែនាំឲ្យបានច្បាស់លាស់ជាមុនសិន។ កត្តាសំខាន់ដែលប្រធានបទត្រូវការចាំបាច់ ទី១ គឺទ្រឹស្តីដែលពាក់ព័ន្ធសម្រាប់ពន្យល់ប្រធានបទមានគ្រប់គ្រាន់ដែរឬទេ? តើអាចទៅរកឯកសារទាំងអស់នោះនៅទីកន្លែងណា? ទី២ គឺជាទិន្នន័យសម្រាប់វិភាគ ទាំងទិន្នន័យដំបូង(Primary data)និងទិន្នន័យទី២ (Secondary data) អាចរកបានតាមវិធីណាខ្លះ? លទ្ធផលស្រាវជ្រាវគួរវិភាគតាមវិធីសាស្ត្របរិមាណវិស័យ (Quantitative method) ឬគុណវិស័យ(Qualitative method) ឬវិធីសាស្ត្រចំរុះ(Mix method)? ដូច្នេះអ្នកស្រាវជ្រាវគួរដឹងចំណុចទាំងអស់នេះឲ្យបានល្អ។

## III. *ការស្នើសុំចុះឈ្មោះប្រធានបទ*

បន្ទាប់ពីបានសម្រេចយកប្រធានបទណាមួយជាក់លាក់ រួចរាល់អស់ហើយ ជាពិសេសមានការឯកភាពពីសាស្ត្រាចារ្យណែនាំផង បេក្ខជនត្រូវយកប្រធានបទដែលបានកំណត់រួចរាល់នោះទៅស្នើសុំចុះបញ្ជីនៅផ្នែកការិយាល័យជំនាញទទួលបន្ទុកស្រាវជ្រាវ(ការិយាល័យ/ដេប៉ាតឺម៉ង់/មជ្ឈមណ្ឌលស្រាវជ្រាវ)។ នីតិវិធីបែបនេះគឺជាការស្នើសុំការអនុញ្ញាតនិងទទួលស្គាល់ជាផ្លូវការសម្រាប់ដំណើការកិច្ចការស្រាវជ្រាវ។ ម្យ៉ាងទៀតការទទួលបានការអនុញ្ញាតនិងទទួលស្គាល់ជាផ្លូវការឲ្យដំណើរការ និងអភិវឌ្ឍន៍ប្រធានបទស្រាវជ្រាវរួចហើយប្រធានបទនោះពុំមានបេក្ខជនណាម្នាក់ផ្សេងទៀតអាចយកទៅសរសេរបានទេ។ ប្រធានបទដែលបានស្នើសុំមុនគេគឺជាកម្មសិទ្ធិរបស់បេក្ខជនដែលបានដាក់ស្នើសុំមុនគេនោះតែម្តង។

## IV. *ដំណើរការសរសេរអត្ថបទស្រាវជ្រាវ*

នៅដំណាក់កាលដំណើការសរសេរអត្ថបទពីមួយចំណុចទៅមួយចំណុច អ្នកស្រាវជ្រាវត្រូវពិនិត្យមើលសារជាថ្មីឡើងវិញគម្រោងស្រាវជ្រាវរបស់ប្រធានបទផ្លូវការនោះ។ ជំហានដំបូងគឺត្រូវកំណត់ចំណុចគន្លឹះមួយចំនួនៈ មានកម្មវត្ថុស្រាវជ្រាវ ចំណោទបញ្ហា ទំហំនិងដែនកំណត់ វិធីសាស្ត្រស្រាវជ្រាវ ផ្នែកទ្រឹស្តីពាក់ព័ន្ធនឹងប្រធានបទ និងតម្រូវការប្រភេទទិន្នន័យ។ល។ ផ្តើមចេញពីចំណុចទាំងអស់នេះ បេក្ខជនត្រូវធ្វើ

ការរៀបចំមាតិកាលម្អិតរបស់ប្រធានបទ៖ មានសេចក្តីផ្តើម ចំនួនជំពូក ចំណងជើងធំ ចំណងជើងរងទី១ ចំណងជើងរងទី២ និងចំណុចបន្តបន្ទាប់។ ការសុំពិគ្រោះយោបល់ជាមួយសាស្ត្រាចារ្យណែនាំនៅតែធ្វើបន្តក្នុងករណីចាំបាច់ ដោះស្រាយបញ្ហាមិនរួចនៅត្រង់ចំណុចខ្លះ ដូចជាការសម្រេចយកទ្រឹស្តីណាមួយដែលសមស្របជាមួយប្រធានបទ ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ និងការវិភាគទិន្នន័យ។ល។ ដូច្នេះដើម្បីសរសេរអត្ថបទស្រាវជ្រាវឲ្យបានល្អ អ្នកស្រាវជ្រាវត្រូវអាននិងធ្វើការស្វែងយល់មេរៀនស្តីពីវិធីសាស្ត្រស្រាវជ្រាវជាមុនសិន ឬចូលស្តាប់សិក្ខាសាលាស្តីពីការស្រាវជ្រាវនិងសរសេរនិក្ខេបបទដោយអ្នកជំនាញជាដើម។

## V. *ការធ្វើបទបង្ហាញសាកល្បង*

អត្ថបទស្រាវជ្រាវបឋមដែលបានសរសេរចប់ឬហៅថាលទ្ធផលស្រាវជ្រាវបឋម តាមធម្មតាត្រូវធ្វើបទបង្ហាញតាមរយៈសិក្ខាសាលាតូចមួយដើម្បីស្ទាបស្ទង់កម្រិតវាយតម្លៃពីសិក្ខាកាមដែលបានមកចូលរួមស្តាប់។ ការរៀបចំធ្វើបទបង្ហាញសាកល្បងត្រូវមានទម្រង់ដូចជាការធ្វើបទបង្ហាញផ្លូវការដែរ។ វាគ្មិនត្រូវរៀបចំដោយខ្លួនឯងនូវកាលបរិច្ឆេទធ្វើបទបង្ហាញ ទីតាំងបន្ទប់ ការចុះឈ្មោះចូលរួមស្តាប់ និងកម្មវិធីធ្វើបទបង្ហាញ។ វាគ្មិនត្រូវរៀបចំខ្លួនឲ្យបានសមរម្យ មានឧបករណ៍គ្រប់គ្រាន់សម្រាប់ធ្វើបទបង្ហាញដូចជា Computer, LCD projector, ឯកសារជា Power point និងឯកសារគាំទ្រអត្ថបទស្រាវជ្រាវសំខាន់ៗមួយចំនួនដែលអាចយកមកជាមួយបាន។ បន្ទាប់ពីធ្វើបទបង្ហាញចប់ ត្រូវទុកពេលឲ្យអ្នកចូលរួមសាកសួរ ជាពិសេសអ្នកជំនាញនិងសាស្ត្រាចារ្យណែនាំចោទសួរ និងបន្ទាប់មកទទួលយកការការរិះគន់កែតម្រូវនិងអនុសាសន៍សំខាន់ៗពីពួកគាត់ដើម្បីធ្វើជាមូលដ្ឋានក្នុងការកែលម្អអត្ថបទស្រាវជ្រាវឲ្យកាន់តែមានកម្រិតគុណភាពប្រសើរឡើង។ ប៉ុន្តែសូមជម្រាបថា*រាល់ការរិះគន់កែតម្រូវនិងការផ្តល់អនុសាសន៍* មួយចំនួនមិនសុទ្ធតែត្រូវទទួលយកទាំងស្រុងនោះទេ ហើយវាថែមទាំងធ្វើឲ្យមានភាពច្របូកច្របល់ទៀត។ ត្រង់ចំណុចនេះ បេក្ខជនត្រូវធ្វើការពិនិត្យឲ្យបានហ្មត់ចត់ ឬអាចសុំពិគ្រោះយោបល់ជាមួយសាស្ត្រាចារ្យណែនាំជាមុនសិន តើគួរទទួលយកចំណុចទាំងនោះមកដាក់បញ្ចូល ឬមិនដាក់បញ្ចូលបន្ថែមនៅក្នុងអត្ថបទស្រាវជ្រាវ? បន្ទាប់ពីទទួលបានការឯកភាពពីសាស្ត្រាចារ្យណែនាំរួចមក បេក្ខជនអាចយកអត្ថបទស្រាវជ្រាវដែលត្រូវបានកំណត់ថាបញ្ចប់ជាស្ថាពរហើយនោះទៅធ្វើការបោះពុម្ពចងក្រងជាសៀវភៅ ដើម្បីយកទៅបង្ហាញផ្នែកជំនាញពិនិត្យបច្ចេកទេសបោះពុម្ព និងស្នើសុំការពារបញ្ចប់ការស្រាវជ្រាវ។ ការការពារសកល្បងគឺជាការបញ្ជាក់សមត្ថភាពនៅចំពោះមុខសាស្ត្រាចារ្យណែនាំបានច្បាស់លាស់ថាបេក្ខជនពិតជាអាចការពាររបាយការណ៍ស្រាវជ្រាវបាន។

## VI. *ការបោះពុម្ពអត្ថបទស្រាវជ្រាវ*

ការបោះពុម្ពអត្ថបទស្រាវជ្រាវបេក្ខជនគួរតែស្វែងយល់និងមានចំណេះដឹងខ្លះដែរ។ ការសរសេរអត្ថបទស្រាវជ្រាវ តាមធម្មតាខាងផ្នែកជំនាញមានសេចក្តីណែនាំពន្យល់ពីការប្រើទំហំក្រដាស(កំណត់យក A4) ទំហំអក្សរ ១១ ឬ ១២ ប្រភេទអក្សរគឺអាស្រ័យទៅតាមការកំណត់របស់សាកលវិទ្យាល័យនីមួយៗ (ឧទាហរណ៍ Unicode: Khmer OS Content ឬ Khmer OS System) គម្លាតគែមក្រដាសខាងឆ្វេង ៣ សង់ទីម៉ែត្រ គម្លាតគែមក្រដាសខាងស្តាំ ២ សង់ទីម៉ែត្រ គម្លាតខាងក្បាលនិងជើងក្រដាស(Top-Bottom) មានប្រវែងស្មើគ្នា ៣ សង់ទីម៉ែត្រ។ ដូច្នេះមុននឹងចាប់ផ្តើមសរសេរអត្ថបទស្រាវជ្រាវ បេក្ខជនត្រូវរៀបចំក្រឹត្យវង្វាស់ឲ្យ

បានត្រឹមត្រូវនៅលើក្រដាស A4 នៃអេក្រង់កុំព្យូទ័រមានដូចជា គម្លាតចេញ ចូលបន្ទាត់ គម្លាតចំណងជើងធំ ចំណងជើងរង គម្លាតចន្លោះបន្ទាត់។ល។ ឲ្យបានចប់សព្វគ្រប់ បន្ទាប់ទៅសឹមចាប់ផ្តើមសរសេរអត្ថបទ ទើបអាចបញ្ចៀសកំហុសបច្ចេកទេសនៃការបោះពុម្ពបានជាអតិបរមា។ តាមបទពិសោធន៍ ការបោះពុម្ពអត្ថបទស្រាវជ្រាវបេក្ខជនត្រូវចេះធ្វើកិច្ចការដោយខ្លួនឯងផ្ទាល់៖ ដូចជាការតុបតែងពណ៌ក្របសៀវភៅឲ្យត្រូវទៅតាមការកំណត់របស់សាកលវិទ្យាល័យ ការរចនាតួអក្សរនៅក្របខាងមុខ ក្របបន្ទាប់។ល។ ប៉ុន្តែបច្ចុប្បន្នដោយមានរោងពុម្ពជាច្រើនអាចជួយធ្វើកិច្ចការទាំងនោះបាន និស្សិតគ្រាន់តែប្រាប់ពីតម្រូវការគឺរោងពុម្ពអាចធ្វើកិច្ចការនោះបានល្អឥតខ្ចោះ ហើយអត្ថបទស្រាវជ្រាវត្រូវបានបោះពុម្ពទៅជាសៀវភៅយ៉ាងល្អដែរ។ សូមបញ្ជាក់ថា ការបោះពុម្ពឯកសារស្រាវជ្រាវនៅដំណាក់កាលនេះពុំទាន់ផ្លូវការនៅឡើយទេ គឺវាគ្រាន់តែជាសៀវភៅបណ្តោះអាសន្នដែលត្រូវចែកជូនទៅគណៈកម្មការដើម្បីពិនិត្យមើលនិងធ្វើការវាយតម្លៃលើអត្ថន័យ ខ្លឹមសារ និងបច្ចេកទេសកិច្ចការស្រាវជ្រាវរបស់បេក្ខជននៅមុនថ្ងៃការពារមកដល់។ រីឯការបោះពុម្ពសៀវភៅសម្រេចចុងក្រោយគឺអាចធ្វើបានក្រោយពីបានការពារបញ្ចប់របាយការណ៍ស្រាវជ្រាវ និងប្រកាសថាជាប់ជាស្ថាពរ។

ខាងក្រោមនេះជាគំនូសបង្ហាញពីការប្រើប្រាស់ទំហំក្រដាស គម្លាតគែមក្រដាស និងប្រភេទតួអក្សរ៖




| របៀបតាក់តែង | ប្រភេទអក្សរ | ទំហំ |
|---|---|---|
| ចំណងជើងធំពូក | KH OS Muol light | 12 |
| ចំណងជើងរង | KH OS Muol light | 11 |
| ចំណងជើងរងបន្ទាប់ | KH OS Muol light | 10.5 |
| ចំណងជើងរងចុងក្រោយ | KH OS Muol light | 10 |
| អត្ថបទសំណេរ: KH OS System | KH OS Content | 11 |
| ដកស្រង់ទាំងស្រុង | KH OS Content | 10 |
| សម្គាល់ក្រោមអក្សរ(Footnote) | KH OS Content | 9 |
| Header & Footer: ត្រូវសរសេរ ចាប់ពីសេចក្តីផ្តើមដល់អនុសាសន៍ | KH OS Content | 8 |
| ចន្លោះបន្ទាត់(Space line)= Multiple: 1.2 cm | | |

ប្រភព៖ (ព័ត៌មានថ្នាក់ក្រោយបរិញ្ញាបត្រ, 2020)

## VII. ការស្នើសុំការពារបញ្ចប់ការស្រាវជ្រាវ

ការបោះពុម្ពសៀវភៅជាបណ្ដោះអាសន្នត្រូវបានធ្វើរួចរាល់ដោយមានការឯកភាពខ្លឹមសារពីសាស្ត្រាចារ្យណែនាំនិងមានការត្រួតពិនិត្យបច្ចេកទេសបោះពុម្ពពីខាងផ្នែកជំនាញផងដែរ។ បេក្ខជននឹងត្រូវឡើងការពារអត្ថបទស្រាវជ្រាវទៅតាមកាលបរិច្ឆេទ ដែលបានរៀបចំដោយដេប៉ាតឺម៉ង់ជំនាញទទួលបន្ទុកកិច្ចការស្រាវជ្រាវជាមួយគណៈកម្មការវាយតម្លៃរបាយការណ៍ស្រាវជ្រាវ។ គណៈកម្មការវាយតម្លៃកិច្ចការស្រាវជ្រាវអាចមានចំនួនបីនាក់ ឬ ប្រាំនាក់ និងមានលេខាកត់ត្រាមួយនាក់។ សមាសភាពគណៈកម្មការមានប្រធានមួយនាក់ អនុប្រធានមួយនាក់ និងសមាជិកមួយនាក់ ឬច្រើនជាងមួយនាក់ ហើយនៅក្នុងនោះសាស្ត្រាចារ្យណែនាំក៏ជាសមាជិកម្នាក់ដែរ។ ដេប៉ាតឺម៉ង់ជំនាញទទួលបន្ទុកកិច្ចការស្រាវជ្រាវធ្វើការបែងចែកអត្ថបទស្រាវជ្រាវដែលបានបោះពុម្ពខាងលើទៅឲ្យសមាជិកគណៈកម្មការម្នាក់មួយច្បាប់ ក្នុងរយៈពេលគ្រប់គ្រាន់យ៉ាងតិចដប់ថ្ងៃដើម្បីត្រួតពិនិត្យនិងវាយតម្លៃបច្ចេកទេសអត្ថបទស្រាវជ្រាវ មុនកាលបរិច្ឆេទការពារបញ្ចប់របាយការណ៍ស្រាវជ្រាវមកដល់។

## VIII. ការធ្វើបទបង្ហាញ និងការពារអត្ថបទស្រាវជ្រាវ

ការធ្វើបបទបង្ហាញ និងការពារអត្ថបទរបាយការណ៍ស្រាវជ្រាវ គឺជាកិច្ចការសំខាន់បំផុតនិងចុងក្រោយរបស់បេក្ខជន។ បេក្ខជនម្នាក់ៗត្រូវរៀបចំឯកសារពាក់ព័ន្ធមួយចំនួននៃរបាយការណ៍ស្រាវជ្រាវឲ្យបានរួចរាល់ទុកសម្រាប់បង្ហាញដល់គណៈកម្មការប្រសិនបើវាជាឯកសារសំខាន់និងចាំបាច់។ របៀបនៃការធ្វើបទបង្ហាញគួរអនុវត្តន៍តាមចំណុចសំខាន់ចំនួនបី ទី១ ការរៀបចំឥរិយាបថ(Style) ទី២ ធ្វើការបង្ហាញអត្ថន័យនិងខ្លឹមសារអត្ថបទស្រាវជ្រាវឲ្យបានច្បាស់ៗ(Meaning) ទី៣ ការបកស្រាយ ពន្យល់ ត្រូវប្រើព្យញ្ជនៈឲ្យបានត្រឹមត្រូវតាមបច្ចេកទេសនិងមានភាពទាក់ទាញដល់អ្នកស្ដាប់(Romance)។ បេក្ខជនត្រូវធ្វើបទបង្ហាញនៅចំពោះមុខគណៈកម្មការវាយតម្លៃកិច្ចការស្រាវជ្រាវក្នុងថេរវេលាប្រមាណ ៣០នាទី និងក្រោយបញ្ចប់កិច្ចធ្វើបទបង្ហាញរបស់បេក្ខជន សមាជិកនៃគណៈកម្មការនឹងធ្វើការចោទសួរនូវសំណួរផ្សេងៗដែលពាក់ព័ន្ធនឹងកិច្ចការស្រាវជ្រាវទាំងមូលរហូតដល់អស់សំណួរក្នុងថេរវេលាប្រមាណ ៣០នាទីដែរ ទើបបញ្ចប់ការធ្វើបទបង្ហាញ។ នៅពេលនោះដែរ បេក្ខជនអាចសម្រាកបាន និងរង់ចាំទទួលស្ដាប់ការប្រកាសលទ្ធផលបន្ទាប់ពីសមាជិកគណៈកម្មការបានធ្វើការពិភាក្សាគ្នារួចរាល់។

## IX. ការប្រកាសលទ្ធផល

លទ្ធផលនៃការស្រាវជ្រាវត្រូវបានផ្ដល់ជាពិន្ទុមធ្យមភាគពីសមាជិកនៃគណៈកម្មការវាយតម្លៃរបាយការណ៍ស្រាវជ្រាវ។ ពិន្ទុដែលប្រកាសថាជាប់ជាស្ថាពរកំណត់ពី ៥០% (ឬ ៦០% ទៅតាមការកំណត់របស់មហាវិទ្យាល័យ ឬសាកលវិទ្យាល័យ) ឡើងទៅ ឬសាកលវិទ្យាល័យខ្លះកំណត់ជានិទ្ទេស(Grade) A, B និង C។ តាមបទពិសោធ លទ្ធផលនៃការការពាររបាយការណ៍ ឬ អត្ថបទស្រាវជ្រាវអាចមានការកំណត់តាមរបៀបផ្សេងៗ ទៅការតាមការកំណត់ជាបច្ចេកទេស ការលើកទឹកចិត្តចំពោះបេក្ខជនដែលបានខិតខំអស់ពីសមត្ថភាព និងបញ្ញាស្មារតីរបស់គណៈកម្មការវាយតម្លៃកិច្ចការស្រាវជ្រាវ។ លទ្ធផលអាចមានបីយ៉ាង៖

- ទី១ ជាប់ទាំងអត្ថន័យ ខ្លឹមសារ វិធីសាស្ត្រស្រាវជ្រាវ និង អត្ថបទសំណេរល្អ អាចតម្កល់បាន។
- ទី២ ជាប់ទាំងអត្ថន័យ ខ្លឹមសារ វិធីសាស្ត្រស្រាវជ្រាវ និង អត្ថបទសំណេរត្រូវបានផ្តល់អនុសាសន៍ឲ្យកែលម្អលើចំណុចខ្វះចន្លោះមួយចំនួន (តិចតួច) តាមការសម្រេចចុងក្រោយរបស់ប្រធានគណៈកម្មការវាយតម្លៃកិច្ចការស្រាវជ្រាវមុននឹងអនុញ្ញាតឲ្យដាក់តម្កល់។
- ទី៣ ជាប់ផ្នែកអត្ថន័យ ខ្លឹមសារ វិធីសាស្ត្រស្រាវជ្រាវ ប៉ុន្តែមិនអនុញ្ញាតឲ្យតម្កល់អត្ថបទសំណេរ។ មានន័យថាបេក្ខជនទទួលបានពិន្ទុនិទ្ទេសជាប់គ្រប់គ្រាន់ ចំណែកអត្ថបទសំណេរគណៈកម្មការវាយតម្លៃកិច្ចការស្រាវជ្រាវមិនអនុញ្ញាតឲ្យតម្កល់ តែបេក្ខជនអាចរក្សាទុកជាឯកសារស្រាវជ្រាវមានប្រយោជន៍សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនបាន។

## សេចក្តីសន្និដ្ឋាន

អត្ថបទសំណេរស្តីពីការរៀបចំកិច្ចដំណើរការគម្រោងប្រធានបទស្រាវជ្រាវនេះគឺជាការរៀបរាប់បទពិសោធន៍មួយដែលធ្លាប់បានជួប បានអនុវត្តន៍ និង កំពុងអនុវត្តន៍លើសកម្មភាពទាំងនោះមកបង្ហាញដល់បេក្ខជន និស្សិតវ័យក្មេងដែលមានបំណងសរសេរអត្ថបទស្រាវជ្រាវដើម្បីបញ្ចប់ការសិក្សា ឬ គ្រូឧទ្ទេសវ័យក្មេងមានបំណងជួយណែនាំនិស្សិតក្នុងការរៀបចំកិច្ចដំណើរការសរសេរអត្ថបទស្រាវជ្រាវអាចមានគំនិតថ្មី ឬជាបទពិសោធន៍បន្ថែមដើម្បីជួយជម្រុញកិច្ចការស្រាវជ្រាវឲ្យមានដំណើការរីកលូតលាស់នៅក្នុងវិស័យអប់រំរបស់យើង។

## Références

Sophie Boutillier et al. (2002). *Méthodologie de la thèse et du mémoire*. Paris: Studyrama.
ព័ត៌មានថ្នាក់ក្រោយបរិញ្ញាបត្រ. (2020). *Graduate Program Prospectus*. Phnom Penh: RULE.